ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៨.....សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែ មេសា ឆ្នាំ២០១៥

# សេចក្ដីណែនាំ
## ស្ដីពី
## នីតិវិធីនៃការទូទាត់ប្រាក់បេសកកម្មក្នុងប្រទេស សម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន

យោងស្មារតីក្នុងកិច្ចប្រជុំបូកសរុបសកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល និងដោយអនុលោមតាមអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ ២០១៤ ស្ដីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ ដែលអនុវត្តថវិកាមិនមែនកម្មវិធី ផ្ដល់អាទិភាពធ្វើការទូទាត់ប្រាក់បេសកកម្មក្នុងប្រទេស (រួមទាំងសោហ៊ុយធ្វើដំណើរ) សម្រាប់ការងារពាក់ព័ន្ធទៅនឹងកិច្ចការខាងលើ ដោយប្រើខ្ទង់ចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ដើម្បីសម្រួលនិងធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការចុះបេសកកម្មរបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន។ ចំពោះក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ ដែលអនុវត្តថវិកាកម្មវិធី ការទូទាត់ប្រាក់បេសកកម្មក្នុងប្រទេសទាំងអស់ត្រូវបានអនុញ្ញាតឱ្យប្រើខ្ទង់ចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទានរួចស្រេចហើយ។ ក្នុងករណីដែលបេសកកម្មក្នុងប្រទេស កើតឡើងមុនការទទួលបានប្រាក់រជ្ជទេយ្យបុរេប្រទានដំបូង ត្រូវធ្វើការទូទាត់ត្រង់ដោយមិនប្រើខ្ទង់ចំណាយរជ្ជទេយ្យបុរេប្រទានទេ។

ទទួលបានសេចក្ដីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយ និងអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798